ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល
សំណុំរឿងរដ្ឋប្បវេណីលេខ ៣៧៩
ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២
សាលក្រមលេខ ០៥២ (ម)
ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២

តាងនាមប្រជារាស្ត្រខ្មែរ
**សាលាដំបូងខេត្តកណ្ដាល**
បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់
នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២
ដោយមានសមាសភាព:

-លោក [redacted] ចៅក្រម
-លោក [redacted] ក្រឡាបញ្ជី

-ដើមចោទឈ្មោះ [redacted] យុទ្ធា ភេទប្រុស កើតថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៨១ កាន់អត្តសញ្ញាណប័ណ្ណលេខ [redacted] ចុះថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៥ អាសយដ្ឋានបច្ចុប្បន្ន [redacted] ។

មេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

-ចុងចម្លើយឈ្មោះ [redacted] សុធារី ភេទស្រី កើតថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៨៤ កាន់អត្តសញ្ញាណប័ណ្ណលេខ [redacted] (០១) ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ អាសយដ្ឋានបច្ចុប្បន្ន [redacted] ។

**អង្គហេតុ និងចំណុចវិវាទ**

**១.ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ:**

១.១.លែងលះ និងរំលាយប័ណ្ណប្រកាសអាពាហ៍ពិពាហ៍លេខ ៤៤០/១៥ កធខ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ ចេញដោយមេឃុំកោះធំ "ខ" ។

១.២.ប្រគល់សិទ្ធិអំណាចមេបាឱ្យទៅចុងចម្លើយ លើកូនចំនួនពីរនាក់ ឈ្មោះ [redacted] បញ្ញារិទ្ធ ភេទប្រុស កើតថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៦ និងឈ្មោះ [redacted] ជូលី ភេទស្រី កើតថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៧ ។

១.៣.ទទួលស្គាល់ឈ្មោះ [redacted] យុទ្ធា និងឈ្មោះ [redacted] សុធារី មិនមានទ្រព្យសម្បត្តិរួម និងបំណុលរួម ។

**២.ការពន្យល់ត្រួសៗអំពីរឿងក្ដី:**

ដើមចោទ និងចុងចម្លើយបានរៀបការជាមួយគ្នាតាមប្រពៃណីកាលពីឆ្នាំ២០១៥ តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ ។ ក្រោយពេលរៀបការរួច ដើមចោទ និងចុងចម្លើយមានកូន០២(ពីរ)នាក់ (ប្រុស០១ស្រី០១) និងមិនមានទ្រព្យសម្បត្តិរួម និងបំណុលរួមទេ ។ ក្រោយពេលរៀបការរួច ដើមចោទ និងចុងចម្លើយរស់នៅជាមួយគ្នាដោយសេចក្ដីសុខសាន្ត ។ បន្ទាប់មកនៅឆ្នាំ ២០១៩ ដើមចោទ និងចុងចម្លើយ រស់នៅជាមួយគ្នាចេះតែមានភាពរកាំរកូស និងមិនចុះសម្រុងនឹងគ្នា ធ្វើឱ្យដើមចោទអស់មនោសញ្ចេតនាជាប្ដីប្រពន្ធនឹងគ្នាតទៅទៀត ទើបដើមចោទដាក់ពាក្យបណ្ដឹងសុំលែងលះមកតុលាការតែម្ដង ។

**៣.ការអះអាងរបស់ភាគី:**

៣.១.មេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្ដីថ្លែងការណ៍ថា៖កូនក្ដីខ្ញុំបានរៀបការជាមួយចុងចម្លើយនៅឆ្នាំ២០១៥ តាមប្រពៃណីខ្មែរ តែមិនបានចុះសំបុត្រអាពាហ៍អាពិហ៍នោះទេ ។ ក្រោយរៀបការរួចកូនក្ដីខ្ញុំ និងចុងចម្លើយមានកូនចំនួន០២(ពីរ)នាក់ ឈ្មោះ [redacted] បញ្ញារិទ្ធ ភេទប្រុស និងឈ្មោះ [redacted] ជូលី ភេទស្រី ចំណែកទ្រព្យសម្បត្តិរួម



Scanned with CamScanner

និងបំណុលរួមមិនមានទេ ។ ក្រោយរៀបការហើយកូនក្តីខ្ញុំរស់នៅចុះសម្រុងគ្នាជាមួយប្រពន្ធដោយសុខសាន្ត ។ ក្រោយមកនៅឆ្នាំ២០១៩ ដោយសារមានភាពរការកូសនឹងគ្នា និងរស់នៅមិនចុះសម្រុងនឹងគ្នាបន្តទៀត កូនក្តីខ្ញុំក៏បានចេញពីផ្ទះទៅរស់នៅជាមួយម្តាយបង្កើតរបស់ខ្លួននៅ[redacted] ។ តាំងពីកូនក្តីខ្ញុំទៅរស់នៅជាមួយម្តាយបង្កើតរបស់ខ្លួន គឺមិនបានទំនាក់ទំនងជាប្រពន្ធ និងកូនៗទេ ដោយសារកូនក្តីខ្ញុំបានទូរស័ព្ទទាក់ទងទៅប្រពន្ធរបស់ខ្លួនដែរ តែប្រពន្ធមិនលើកទូរស័ព្ទកូនក្តីខ្ញុំឡើយ ។ ដោយសារតែកូនក្តីខ្ញុំអស់មនោសញ្ចេតនាជាមួយប្រពន្ធបន្តទៅទៀត ទើបកូនក្តីខ្ញុំបានដាក់ពាក្យបណ្តឹងសុំលែងលះជាមួយចុងចម្លើយ ដូចមានកម្មវត្ថុក្នុងពាក្យបណ្តឹងលែងលះចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ ។ ហើយនៅពេលនេះ កូនក្តីខ្ញុំនៅតែធ្វើការទាមទារដូចក្នុងកម្មវត្ថុនៃពាក្យបណ្តឹងលែងលះចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ ដដែល ។

៣.២.**ដើមចោទឈ្មោះ** [redacted] **យុទ្ធា** បានថ្លែងការណ៍ថា៖ ខ្ញុំឯកភាពតាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យខ្ញុំបាទទាំងស្រុង ។

៣.៣.ចុងចម្លើយឈ្មោះ [redacted] **សុធារី** បានធ្វើសេចក្តីថ្លែងការណ៍ថា៖ នាងខ្ញុំពិតជាបានរៀបការជាមួយគ្នាក្នុងឆ្នាំ២០១៥ តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ប្រាកដមែន ។ ក្នុងការរស់នៅជាមួយគ្នា មានកូនចំនួន០២(ពីរ)នាក់ (ប្រុស០១ស្រី០១) ។ នៅពេលនេះនាងខ្ញុំយល់ព្រមលែងលះជាមួយដើមចោទ ព្រោះរស់នៅមិនចុះសម្រុងនឹងគ្នា ។ ទី២.ខ្ញុំយល់ព្រមទទួលសិទ្ធិអំណាចមេបាលើកូនទាំង០២(ពីរ)នាក់ តែទាមទារប្រាក់អាហារកិច្ចសម្រាប់ចិញ្ចឹមកូនផ្តាច់ពីដើមចោទចំនួន៣.០០០(បីពាន់)ដុល្លារអាមេរិក ។ ទី៣.នាងខ្ញុំ និងដើមចោទពិតជាគ្មានទ្រព្យសម្បត្តិរួម និងបំណុលរួមនោះទេ ។

៣.៤.ដើមចោទឈ្មោះ [redacted] **យុទ្ធា** បានថ្លែងការណ៍តបថា៖ ដើមចោទទាមទារប្រាក់អាហារកិច្ចសម្រាប់ចិញ្ចឹមកូនផ្តាច់ចំនួន៣.០០០(បីពាន់)ដុល្លារអាមេរិក គឺខ្លួនមិនមានលទ្ធភាពនោះទេ ដោយសារខ្លួនអត់មានការងារធ្វើទេ ។ បើដើមចោទទាមទារអាហារកិច្ចចិញ្ចឹមកូន ខ្ញុំសូមទាមទារសិទ្ធិអំណាចមេបាលើកូន០១(មួយ)នាក់វិញ គឺចែកកូនម្នាក់មួយ ។

**៤.ចំណុចវិវាទ៖** ការប្តឹងសុំលែងលះ ។

**៥.ចំណុចគ្មានវិវាទ៖** ដើមចោទសូមប្រគល់សិទ្ធិអំណាមេបាលើកូនទាំង០២នាក់ឱ្យទៅចុងចម្លើយ ហើយចុងចម្លើយបានយល់ព្រម ។

**៦.ភស្តុតាងជាឯកសារមាន:**

-ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍លេខ ៤៤០/១៥ កធ.ខ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់មន្ត្រីអត្រានុកូលដ្ឋានឃុំកោះធំ “ខ” ។

-សំបុត្រកំណើតលេខ ១១៨ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦ របស់មន្ត្រីអត្រានុកូលដ្ឋានឃុំកោះធំ “ខ” ។

-សំបុត្រកំណើតលេខ ០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៧ របស់មន្ត្រីអត្រានុកូលដ្ឋានឃុំកោះធំ “ខ” ។

## សំអាងហេតុ

១.ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតាមប្រពៃណី តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់នោះទេ ។ ដូច្នេះឃើញថាដើមចោទ និងចុងចម្លើយមិនបានបំពេញករណីកិច្ចជាប្តីប្រពន្ធស្របច្បាប់ ដែលអាចឱ្យតុលាការលើកយកមកពិចារណាសម្រេចអំពីការសុំលែងលះ ដោយយោងតាមបញ្ញត្តិមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណីនោះទេ ។

២.ដើមចោទបានសុំប្រគល់សិទ្ធិអំណាចមេបាលើកូនចំនួន០២(ពីរ)នាក់ ១.ឈ្មោះ [redacted]បញ្ញារិទ្ធ ភេទប្រុស កើតថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៦ និង២.ឈ្មោះ [redacted]ជូលី ភេទលី កើតថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៧ ឱ្យទៅដើមចោទជាអ្នកគ្រប់គ្រង ហើយចុងចម្លើយបានយល់ព្រមទទួលយកសិទ្ធិអំណាចមេបាលើកូនទាំង០២(ពីរ)នាក់ដែរ ។ ដូចនេះតុលាការគប្បីពិចារណាសម្រេចការព្រមព្រៀងរបស់គូភាគី ។

៣.ចុងចម្លើយទាមទារប្រាក់អាហារកិច្ចផ្គត់ផ្គង់ចំនួន៣.០០០(បីពាន់)ដុល្លារអាមេរិក តែដើមចោទបដិសេធ ដោយហេតុថាខ្លួនមិនមានលទ្ធភាព ។ ដូចនេះតុលាការគប្បីពិចារណាសម្រេចតាមច្បាប់ ។

៤.ដើមចោទទាមទារសុំឱ្យតុលាការទទួលស្គាល់ថា មិនមានទ្រព្យសម្បត្តិរួម និងបំណុលរួមទេ ហើយចុងចម្លើយក៏បានបញ្ជាក់ថាមិនមានទ្រព្យសម្បត្តិរួម និងបំណុលរួមដែរ ។ ឃើញថាគូភាគីពុំមានទ្រព្យសម្បត្តិ និងបំណុលរួម គប្បីតុលាការពុំលើកយកមកពិចារណាសម្រេចយ៉ាងណាមាត្រា ៩៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណីនោះទេ ។

៥.ចំពោះប្រាក់ប្រដាប់ក្ដី តុលាការគប្បីសម្រេចតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្ដីសម្រេចបញ្ចប់

១.ប្រកាសចោលការទាមទារលែងលះរបស់ដើមចោទឈ្មោះ [redacted] យុទ្ធា ។ បំបែកលំនៅសង្វាស់រវាងដើមចោទឈ្មោះ [redacted] យុទ្ធា ភេទប្រុស កើតថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៨១ កាន់អត្តសញ្ញាណប័ណ្ណលេខ [redacted] ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ អាសយដ្ឋានបច្ចុប្បន្ននៅ [redacted] និងចុងចម្លើយឈ្មោះ [redacted] សុផារី ភេទស្រី កើតថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៨៤ កាន់អត្តសញ្ញាណប័ណ្ណលេខ [redacted](០១) ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ អាសយដ្ឋានបច្ចុប្បន្នភូមិ [redacted] ហើយគូភាគីមានសិទ្ធិជ្រើសរើសយកគូស្រករថ្មីបាន ។

២.ប្រគល់សិទ្ធិអំណាចមេបាលើកូនចំនួន០២(ពីរ)នាក់ ១.ឈ្មោះ [redacted] បញ្ញាវិទ្ធ ភេទប្រុស កើតថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៦ និង២.ឈ្មោះ [redacted] ផូលី ភេទលី កើតថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៧ ឱ្យទៅចុងចម្លើយឈ្មោះ [redacted] សុផារី ជាម្ដាយ ។ ទុកសិទ្ធិឱ្យដើមចោទជាឪពុក ដែលមិនបានទទួលសិទ្ធិអំណាចមេបាលើកូន ទៅសាកសួរសុខទុក្ខប្រាស្រ័យទាក់ទងជាមួយកូន និងផ្ដល់ប្រាក់អាហារកិច្ចចិញ្ចឹមកូនតាមលទ្ធភាព ។

៣.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ និងចុងចម្លើយ ។

សាលក្រមនេះប្រកាសជាសាធារណៈ នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២ ចំពោះមុខគូភាគី បើកសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ចៅក្រម**

ហត្ថលេខា និងត្រា៖ [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៩កើត ខែកត្ដិក ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅខេត្តកណ្ដាល.ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

កណ្ដាល, ថ្ងៃទី 02 ខែ 11 ឆ្នាំ 2022

ក្រឡាបញ្ជី

[redacted]